ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ៣២/១២-ក្លូប័ល អាប៉ារែល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ឈីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត
អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៩៥០ ៩៥៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក វី វ៉ាន់ឡូ | ប្រធានធនធានមនុស្ស |
| ២- លោក សួង ភន | មន្ត្រីទំនាក់ទំនងវិវាទការងារ |
| ៣- លោក គឹម សំអាង | ជំនួយការប្រធានគ្រប់គ្រងធនធានមនុស្ស |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- សហព័ន្ធសហជីពកម្មករនិយោជិត
- សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ក្លូប័ល អាប៉ារែល

អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៩៩៥ ៥២៣ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត ៖

១- លោក តែប គុន មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត

២- លោក ខៀវ ប៊ុនសែន មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតផ្នែកស៊ីបភីងទាមទារឱ្យក្រុមហ៊ុនលោកផ្លាស់ប្តូរលោក អ៊ី ឆាយអ៊ីង ចេញពីផ្នែកស៊ីបភីង។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា មិនអាចផ្លាស់ប្តូរលោក អ៊ី ឆាយអ៊ីង ចេញពីផ្នែកស៊ីបភីងបានទេ។

២- កម្មករនិយោជិតផ្នែកស៊ីបភីងទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់បន្ថែមម៉ោង និងប្រាក់ថ្លៃបាយ នៅពេលធ្វើការបន្ថែមម៉ោង។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា សុំទុកបញ្ហានេះយកទៅពិភាក្សាជាមួយថៅកែសិន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៨០ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ (វេលាម៉ោង ២ រសៀល)។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករនិយោជិត ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន

០២ ចំណុច លើការទាមទារចំនួន ០៤ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៨០ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នាឱ្យសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ច ក្នុងការអនុវត្តសេចក្តីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ចសម្រាប់ចំណុចវិវាទទាំងអស់។

ភាគីនៃសំណុំរឿងនេះ បានឯកភាពពន្យាពេលនៃការចេញសេចក្តីបង្គាប់របហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតរបស់នាយកក្រុមហ៊ុន ក្លូប័ល អាប៉ារែល គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

ស្តីពីផ្ទេរសិទ្ធិជូនលោក វី វ៉ាន់ឡូ សំរាប់សវនាការសំណុំរឿងលេខ ៣២/១២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១២ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ក្លូប័ល អាប៉ារែល លេខ ១៨០ កប/អក/វក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ក្លូប័ល អាប៉ារែល ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៨ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៨៩ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត មានជួលកម្មករនិយោជិតចំនួន ២៥៧០ នាក់។
- សហជីពកម្មករនិយោជិតជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតផ្នែកស៊ីបភីង (ផ្នែកដឹកជញ្ជូន) ទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូរលោក អ៊ី ឆាយអ៊ីង ចេញពីផ្នែកស៊ីបភីង

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ថា សហជីពកម្មករនិយោជិតធ្លាប់បានទាមទារម្តងរួចមកហើយ គឺនៅក្នុងសំណុំរឿងលេខ ១៧៥/១១-ក្លូប័ល អាប៉ារែល ដែលអង្គហេតុនៃសំណុំរឿងទាំងពីរមានភាពដូចគ្នា។
- នៅក្នុងសំណុំរឿងលេខ ១៧៥/១១-ក្លូប័ល អាប៉ារែល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេច បដិសេធការទាមទាររបស់បុគ្គលិក ឱ្យនិយោជកផ្លាស់ប្តូរ លោក អ៊ី ឆាយអ៊ីង ចេញពីផ្នែកស៊ីបភីង។

ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតផ្នែកស៊ីបភីងទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់បន្ថែមម៉ោង និងប្រាក់ថ្លៃបាយនៅពេលធ្វើការបន្ថែមម៉ោង

- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកស៊ីបភីងចំនួន ១៣ នាក់ ដែលជាភាគីដើមបណ្តឹង បានលាឈប់ពីការងារអស់ហើយ។ ដូចនេះ នៅក្នុងចំណុចវិវាទនេះ មិនមានកម្មករនិយោជិតដែលជាដើមបណ្តឹងជាក់លាក់ទាមទារក្នុងចំណុចនេះទៀតទេ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

មុននឹងពិចារណាចំណុចវិវាទទាំង២នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញាមួយណាមួយចែងពីការទាមទារនោះ"* ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ឹម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ហ្គូល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទទី១ (ការទាមទារឱ្យផ្លាស់ប្តូរបុគ្គលិកក្រុមហ៊ុន), ចំណុចវិវាទទី២ (ប្រាក់បន្ថែមម៉ោង និងប្រាក់ថ្លៃបាយនៅពេលធ្វើការបន្ថែមម៉ោង) គឺជាវិវាទអំពីសិទ្ធិ ព្រោះវិវាទទាំងនេះពាក់ព័ន្ធនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ស្តីពីការងារ ។

ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតផ្នែកស៊ីបភីងទាមទារឱ្យក្រុមហ៊ុនផ្លាស់ប្តូរលោក អ៊ី ឆាយអ៊ីង ចេញពីផ្នែកស៊ីបភីង

ចំណុចវិវាទ ដែលសហជីពកម្មករនិយោជិតកំពុងតែទាមទារនៅក្រុមហ៊ុន ក្លូប៉ល អាប៉ារ៉ែល លីមីធីត នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ម្តងរួចមកហើយ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ ក្នុងសំណុំរឿងលេខ១៧៥/១១។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវសម្រេចលើចំណុចវិវាទនេះម្តងទៀតដែរ ឬទេ?

ផ្អែកតាមគោលការណ៍ " *អាជ្ញាអស់ជំនុំ (res judicata)*" គឺជាគោលការណ៍ផ្លូវច្បាប់ ដែលសំណុំរឿងមួយត្រូវបាននាំមកដោយភាគីវិវាទដដែល ទៅលើចំណុចវិវាទដដែលមកកាន់អង្គជំនុំជំរះមួយ ហើយអង្គជំនុំជំរះនោះ បានចេញសេចក្តីសម្រេចលើចំណុចវិវាទនោះរួចហើយ អង្គជំនុំជំរះមានឆន្ទានុសិទ្ធិក្នុងការលើកយកវិវាទនេះមកពិចារណា ឬមិនលើកយកមកពិចារណាសម្រេចម្តងទៀតបាន លើកលែងតែមានច្បាប់ជាធរមានចែងផ្ទុយពីនេះ។

ផ្អែកតាមគោលការណ៍នេះ ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនឃើញមានបទប្បញ្ញត្តិច្បាប់ណាមួយចែងពីបញ្ហានេះទាក់ទងនឹងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូច្នេះ នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើចំណុចវិវាទមួយរួចហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានឆន្ទានុសិទ្ធិក្នុងការពិចារណាថា តើ

ARBITRATION COUNCIL

ត្រូវលើកយកចំណុចវិវាទនោះមកសម្រេចសារជាថ្មីឡើងវិញឬទេ (សូមមើលសេចក្ដីបង្គាប់លេខ *៤៥/០៧-វិល សិន ហេតុផលចំណុចវិវាទទី២. លេខ ១៤/០៨-ឃ្វីក ស៊ូ ហេតុផលចំណុចវិវាទទី១. លេខ ៦៤/០៩-ស៊ីណូមេក ២* និងលេខ *៩៥/០៩-តាកហ្វាត ហេតុផលចំណុចវិវាទទី៣*) ។

ទាក់ទងនឹងគោលការណ៍ "*អាជ្ញាអស់ជំនុំ (res judicata)*" នេះដែរ នៅក្នុងសំណុំរឿងលេខ ៤២/០៧-សៅ ធន់បេ ចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា គួរបដិសេធពិចារណាលើការទាមទាររបស់កម្មករនិយោជិត ប្រសិនបើចំណុចវិវាទនេះ បំពេញលក្ខខណ្ឌចំនួន៣ គឺ ៖

(១) ភាគីវិវាទធ្លាប់ចូលរួមលើចំណុចវិវាទនេះពីមុនមក

(២) ចំណុចវិវាទដែលធ្លាប់នាំមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល និង

(៣) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសម្រេចលើអង្គសេចក្ដីចប់សព្វគ្រប់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងដដែលបានលើកឡើងបន្ថែមទៀតថា គោលបំណងនៃការបដិសេធការពិចារណាលើចំណុចទាមទារដដែលសារជាថ្មី គឺដើម្បីជៀសវាងមិនឱ្យមានលទ្ធផលផ្ទុយគ្នា ចំពោះដំណោះស្រាយវិវាទដដែល និងដើម្បីឱ្យការដោះស្រាយវិវាទត្រូវបានបញ្ចប់ដោយមានសេចក្ដីសម្រេចមួយជាចុងក្រោយ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះក៏យល់ស្របលើការបកស្រាយខាងលើដែរ ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីកម្មករនិយោជិតដែលនាំវិវាទមកនៅក្នុងនៅក្នុងសំណុំរឿងនេះ គឺជាភាគីតែមួយនៅក្នុងសំណុំរឿងលេខ១៧៥/១១-ក្លូប័ល អាប៉ារែល ហើយក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសម្រេចលើអង្គសេចក្ដីចប់សព្វគ្រប់ហើយ ។

ដូចនេះ ផ្អែកលើគោលការណ៍ "*អាជ្ញាអស់ជំនុំ (res judicata)*" និងដើម្បីឱ្យស្របនឹងសេចក្ដីសម្រេចនៃសេចក្ដីបង្គាប់មុនក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកផ្លាស់ប្ដូរលោក អ៊ី ឆាយអ៊ុង ចេញពីផ្នែកស៊ីបភីង ។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតផ្នែកស៊ីបភីងទាមទារឱ្យក្រុមហ៊ុនផ្ដល់ប្រាក់បន្ថែមម៉ោង និងប្រាក់ថ្លៃបាយនៅពេលធ្វើការបន្ថែមម៉ោង**

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកស៊ីបភីងចំនួន១៣ នាក់ ដែលជាភាគីដើមបណ្ដឹងបានលាឈប់ពីការងារអស់ហើយ ។ ដូចនេះ នៅក្នុងចំណុចវិវាទនេះ មិនមានកម្មករនិយោជិត ដែលជាភាគីដើមបណ្ដឹងជាក់លាក់ទាមទារក្នុងចំណុចនេះទៀតទេ ។

ដោយសារនៅក្នុងករណីនេះ មិនមានកម្មករនិយោជិតដែលជាដើមបណ្ដឹងជាក់លាក់ទាមទារចំណុចនេះទៀត ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្ដល់ប្រាក់បន្ថែមម៉ោង និងប្រាក់ថ្លៃបាយនៅពេលធ្វើការបន្ថែមម៉ោង ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ ៖

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

ចំណុចវិវាទទី១ ៖ បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្លាស់ប្តូរលោក អ៊ី ឆាយអ៊ុង ចេញពីផ្នែកស៊ុបភីង ។

ចំណុចវិវាទទី២ ៖ បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់បន្ថែមម៉ោង និង ប្រាក់ថ្លៃបាយនៅពេលធ្វើការបន្ថែមម៉ោង ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះ ចេញទៅដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ ៖ **អ៊ុច សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល:

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ------------------------------